# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

**អ្នកនាំពាក្យ គ.ជ.ប**

**លេខ ១១២ គ.ជ.ប**

ថ្ងៃសុក្រ ១កើត ខែទុតិយាសាឍ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែកក្កដា ឆ្នាំ២០១៨

## សេចក្តីប្រកាសព័ត៌មាន
### ការស្វែងរកទីតាំងការិយាល័យបោះឆ្នោតតាម Google Map

ដើម្បីកាន់តែមានភាពងាយស្រួលស្វែងរកទីតាំងការិយាល័យបោះឆ្នោត គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត បានផលិតកម្មវិធីគ្រប់គ្រង និងការស្វែងរកផែនទីឈ្មោះទីតាំងការិយាល័យបោះឆ្នោត តាមផែនទីក្នុងប្រព័ន្ធអ៊ីនធឺណិត ហើយបានដាក់ឱ្យដំណើរការតាមរយៈគេហទំព័រ www.pollingstation.org.kh នៅថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០១៨ នេះតទៅ ។

កម្មវិធីនេះ អនុញ្ញាតឱ្យភាគីពាក់ព័ន្ធទាំងអស់ចូលស្វែងរកទីតាំងការិយាល័យបោះឆ្នោត ក្នុងផែនទីប្រទេសកម្ពុជា ដែលមានរក្សាទុកក្នុង Google Map បានយ៉ាងឆាប់រហ័សតាមប្រព័ន្ធអ៊ីនធឺណិត សម្រាប់បម្រើឱ្យការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៦ ឆ្នាំ២០១៨។

របៀបប្រើប្រាស់កម្មវិធី ៖ លោកអ្នកចូលទៅកាន់គេហទំព័រ www.pollingstation.org.kh ដើម្បីស្វែងរកទិន្នន័យតាមរយៈការជ្រើសរើស ឃុំ សង្កាត់ ក្រុង ស្រុក ខណ្ឌ និងរាជធានី ខេត្ត ឬស្វែងរកទីតាំងតាមផែនទី Google Map ដោយចុចតាមនិមិត្តសញ្ញាសម្គាល់ទីតាំងគណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោតទាំង ២៥ ។

យោងតាមលទ្ធផលផ្លូវការនៃការធ្វើបច្ចុប្បន្នភាពបញ្ជីបោះឆ្នោត និងការចុះឈ្មោះបោះឆ្នោត ឆ្នាំ២០១៧ សម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៦ ឆ្នាំ២០១៨ ប្រជាពលរដ្ឋដែលមានឈ្មោះនៅក្នុងបញ្ជីបោះឆ្នោតមានចំនួន **៨.៣៨០.២១៧** នាក់ ( www.necelect.org.kh/khmer/content/2865 ) ។ ប្រជាពលរដ្ឋដែលមានឈ្មោះក្នុងបញ្ជីបោះឆ្នោត ឆ្នាំ២០១៧ អាចពិនិត្យមើលឈ្មោះ និងទិន្នន័យពាក់ព័ន្ធរបស់ខ្លួនលើគេហទំព័រ www.voterlist.org.kh ផងដែរ ។

ចំពោះព័ត៌មានពិស្តារ សូមទាក់ទង!


| | |
|---|---|
| ឯកឧត្តម **ហង្ស ពុទ្ធា** សមាជិក និងជាអ្នកនាំពាក្យ គ.ជ.ប | ឯកឧត្តម **ឌីម សុវណ្ណារំ** សមាជិក និងជាអ្នកនាំពាក្យ គ.ជ.ប |
| Tel: (855)12 959 666 | Tel: (855)12 518 485 |
| Email : hangputhea@gmail.com | Email : sovannaromhy@yahoo.fr |